ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ១៦៩៤ អក
ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣
សាលក្រមព្រហ្មទណ្ឌ
លេខ ៤០/ខ
ចុះថ្ងៃ១៣ ខែមីនា ឆ្នាំ២០២៤

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្តាល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤ វេលាម៉ោង ០៩ និង ០០នាទីព្រឹក ដោយមានសមាសភាពចូលរួមដូចខាងក្រោម ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ចៅក្រមប្រឹក្សា
លោកស្រី [redacted] ចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្តាល

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្តាល

### មេធាវីការពារសិទ្ធិជនជាប់ចោទ

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] រក្សា

-ដើម្បីធ្វើការជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១៦៩៤ អក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទដូចខាងក្រោម ៖

១-ឈ្មោះ [redacted] រក្សា ហៅ ហ៊ីង ភេទប្រុស អាយុ១៦ ឆ្នាំ(កើតឆ្នាំ២០០៧) ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] សេង (រស់) ម្តាយឈ្មោះ [redacted] ចាន់រ៉េត (រស់) នៅលីវ ជាអនីតិជន ទោសពីមុន៖ គ្មាន ។(ក្នុងឃុំ)

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៤៥០៤ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល។

២-ឈ្មោះ [redacted] ប្រុសម៉ី ភេទប្រុស អាយុ២៣ ឆ្នាំ ជនជាតិខ្មែរ មុខរបរ អ្នកបញ្ចូលកំប៉ុងហ្គាស មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] សុភ័ក្ត្រ (រស់) ម្តាយឈ្មោះ [redacted] ស្រីមុំ (រស់) នៅលីវ ជានីតិជន ទោសពីមុន៖ គ្មាន ។(ក្នុងឃុំ)



Scanned with CamScanner

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៤៥០៦ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល។

ជាប់ចោទពីបទ **លួច (ដោះគ្រឿងបំណែកម៉ាស៊ីនបូមខ្សាច់) និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិស្រែខ្សាច់ ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្ដាល កាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣ បទល្មើសដែលបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

-ជនរងគ្រោះឈ្មោះ [redacted] អួន ភេទប្រុស អាយុ៥០ ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានទីលំនៅបច្ចុប្បន្ននៅភូមិស្រែខ្សាច់ ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្ដាល។

-បានឃើញ របាយការណ៍សរុបលេខ ១២២/២០២៣ របក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ របស់អធិការដ្ឋាននគរបាលស្រុកកៀនស្វាយ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៖ ១៣៤៦ ដកសស ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៖ ១៣៦៨ ដកសព ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

-បានឃើញ ដីកាដំណោះស្រាយលេខ ៖ ១៣៨០ ដកដស ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្ដាល ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង១៣ និង៣៥នាទី មានករណី លួច(ដោះគ្រឿងបំណែក ម៉ាស៊ីនបូមខ្សាច់) ស្ថិតនៅភូមិស្រែខ្សាច់ ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្ដាល បង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ប្រុសម៉ី ភេទប្រុស អាយុ២៣ឆ្នាំ និងឈ្មោះ [redacted] រក្សា ភេទប្រុស អាយុ១៦ឆ្នាំ បានធ្វើសកម្មភាពលួច ដោះគ្រឿងបំណែកម៉ាស៊ីនបូមខ្សាច់របស់ជនរងគ្រោះឈ្មោះ [redacted] អួន ភេទប្រុស អាយុ៥០ឆ្នាំ ពេលកំពុងធ្វើសកម្មភាព ជនរងគ្រោះមកទាន់ ហើយស្រែកថា ចោរៗ រួចបានដេញចាប់ជនជាប់ចោទទាំងពីរនាក់។ ពេលកំពុងដេញ នោះជនជាប់ចោទបានយកដំបងឈើដេញវាយជនរងគ្រោះវិញ ដោយមានការភ័យខ្លាចជនរងគ្រោះបានត្រឡប់មកការដ្ឋានវិញ បន្ទាប់មកជនជាប់ចោទទាំងពីរនាក់បានរត់គេចខ្លួនបាត់ ដោយបន្សល់ទុកនៅម៉ូតូ និងសម្ភារៈកូនសោរ សម្រាប់ដោះម៉ាស៊ីនមួយចំនួននៅនឹងកន្លែងកើតហេតុ។ ក្រោយមកជនរងគ្រោះបានទៅដាក់ពាក្យបណ្ដឹងនៅកងរាជអាវុធហត្ថខេត្តកណ្ដាល ហើយឃាត់ខ្លួនបានជនជាប់ចោទទាំងពីរនាក់ខាងលើតែម្ដង។ តាមកំណត់ហេតុធ្វើតេស្ត ទឹកនោមរបស់ឈ្មោះ [redacted] ប្រុសម៉ី និងឈ្មោះ [redacted] រក្សា គឺមានផ្ទុកនូវសារធាតុញៀន (+) ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] រក្សា បានឆ្លើយថា៖ ខ្លួនទទួលស្គាល់បទចោទប្រកាន់របស់តុលាការ ខ្លួន និងឈ្មោះ [redacted] ប្រុសម៉ី ពិតជាបានធ្វើសកម្មភាពលួចដោះខ្សែខ្សង គ្រឿងបំណែកម៉ាស៊ីនរបស់គេប្រាកដមែន។ ខ្លួនទើបតែប្រព្រឹត្តបទល្មើសលើកដំបូងតែប៉ុណ្ណោះ។



Scanned with CamScanner

-ជនជាប់ចោទឈ្មោះ [redacted] ប្រុសម៉ី បានឆ្លើយថា៖ ខ្លួនទទួលស្គាល់បទចោទប្រកាន់របស់តុលាការ ខ្លួន និងឈ្មោះ [redacted] ប្រុសម៉ី ពិតជាបានធ្វើសកម្មភាពលួចដោះខ្ទៅខ្យង គ្រឿងបំណែកម៉ាស៊ីនរបស់គេប្រាកដមែន។ ខ្លួនបានទៅរកឃ្លុំក៏ឃើញម៉ាស៊ីនគេទុកចោល ហើយខ្លួនក៏លួចដោះបំណែកម៉ាស៊ីនរបស់គេ តែម្តង។ ខ្លួនប្រើប្រាស់គ្រឿងញៀនបានប្រហែល ០៥ ថ្ងៃ មុនចាប់ខ្លួន។ ខ្លួនប្រើប្រាស់គ្រឿងញៀនជាមួយឈ្មោះ [redacted] រក្សា ។

-តាមអំណានចម្លើយជនរងគ្រោះឈ្មោះ [redacted] អូន បានឆ្លើយថា៖ កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង ១៣ និង ៣៥នាទី ខ្លួនកំពុងនៅផ្ទះជាប់នឹងការដ្ឋានបូមខ្សាច់ បានឮសំឡេងគេដោះម៉ាស៊ីន បានដើរទៅមើលឃើញជនជាប់ចោទចំនួន ២នាក់ និងម៉ូតូ ១គ្រឿងម៉ាកសង់កូរ៉េ ឈប់ក្បែរនោះ ។ ដោយពួកវាកំពុងដោះម៉ាស៊ីន ឃើញដូច្នេះខ្លួនបានដើរទៅលួច ស្រែកថា ចោរៗ ពួកវាបានរត់ ខ្លួនបានដេញពីក្រោយ បន្ទាប់មកពួកវាក៏បានយកដំបងឈើដេញខ្លួនវិញ តែមិនបណ្តាលឱ្យខ្លួនមានរបួសទេ ។ ក្រោយមកពួកវាបានហែលឆ្លងទឹកស្ទឹង គេចខ្លួនតែម្តង។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ឆ្លងតាមការសួរដេញដោលនាពេលសវនាការ ឃើញថាចម្លើយជនជាប់ចោទឈ្មោះ [redacted] រក្សា ហៅ ហ៊ីង និងឈ្មោះ [redacted] ប្រុសម៉ី បានឆ្លើយសារភាពថាពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់មែន ហេតុនេះតំណាងអយ្យការស្នើសុំរក្សាបទចោទប្រកាន់ដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរលេខ ១៣៦៨ ដកសព ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៣ និងស្នើសុំតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] រក្សា ភេទប្រុស អាយុ ១៦ ឆ្នាំ បានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានសួរដេញដោលនាពេលសវនាការ កូនក្តីខ្លួនបានឆ្លើយសារភាពគ្រប់ដំណាក់កាលថា ពិតជាបានប្រព្រឹត្ត ដូចការចោទប្រកាន់ប្រាកដមែន។ ហេតុដូច្នេះ សូមតុលាការមេត្តាជួយផ្តល់ស្ថានសម្រាលដល់កូនក្តីខ្លួន ស្របតាមមាត្រា ៩៣,៩៤ នៃក្រមព្រហ្មទណ្ឌ។

**សំដីចុងក្រោយរបស់ជនជាប់ចោទ** សូមឱ្យក្រុមប្រឹក្សាជំនុំជម្រះជួយបន្ធូរបន្ថយទោសដល់ពួកខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយជនរងគ្រោះ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានពិនិត្យកស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

# សំអាងហេតុ

១.កាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣ ប្រព្រឹត្តនៅភូមិស្រែខ្សាច់ ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល ពិតជាមានករណី លួច (**ដោះគ្រឿងបំណែកម៉ាស៊ីនបូមខ្សាច់**) **និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** កើតឡើងប្រាកដមែន។



Scanned with CamScanner

២.ជនជាប់ចោទឈ្មោះ [redacted] រក្សា ហៅ ហ៊ីង និងឈ្មោះ [redacted] ប្រុសម៉ី បានឆ្លើយសារភាពថា ពួកខ្លួនពិតជាបានធ្វើសកម្មភាពលួចដោះបំណែកម៉ាស៊ីនរបស់ជនរងគ្រោះ ពិតប្រាកដមែន។

៣.ជនជាប់ចោទឈ្មោះ [redacted] រក្សា ហៅ ហ៊ីង និងឈ្មោះ [redacted] ប្រុសម៉ី មានស្មារតីដឹងខុសត្រូវគ្រប់គ្រាន់ក្នុងការប្រព្រឹត្តបទល្មើស ពុំមានសញ្ញាណណាមួយបង្ហាញថា ជនជាប់ចោទមានវិបល្លាសស្មារតីនោះទេ។

៤.អំពើល្មើសរបស់ជនជាប់ចោទឈ្មោះ [redacted] រក្សា ហៅ ហ៊ីង និងឈ្មោះ [redacted] ប្រុសម៉ី បានធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈរបៀបរៀបរយសង្គមជាខ្លាំង និងប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់អ្នកដទៃ ដែលច្បាប់បានហាមឃាត់។

៥.ការស្នើសុំរបស់តំណាងអយ្យការនៅក្នុងដីកាសន្និដ្ឋានស្ថាពរ មានមូលដ្ឋានគ្រប់គ្រាន់ដោយឈរលើកស្តុតាង អង្គហេតុ និងអង្គច្បាប់ ដែលអាចឱ្យតុលាការមានមូលដ្ឋានក្នុងការពិចារណា ដើម្បីសម្រេចបាន។

៦.តំណាងអយ្យការប្តឹងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ដែលចំណុចនេះ គប្បីតុលាការពិចារណា។

៧.មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] រក្សា ហៅ ហ៊ីង និងឈ្មោះ [redacted] ប្រុសម៉ី ពីបទ លួច (ដោះគ្រឿងបំណែកម៉ាស៊ីនបូមខ្សាច់) និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិស្រែខ្សាច់ ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣ បទល្មើសដែលបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៨-ជនជាប់ចោទឈ្មោះ [redacted] រក្សា ហៅ ហ៊ីង ភេទប្រុស អាយុ១៦ ឆ្នាំ(កើតឆ្នាំ២០០៧) ជាអនីតិជន គប្បីតុលាការសម្រេច និងប្រកាសទោសដែលត្រូវអនុវត្តចំពោះអនីតិជន តាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

៩-ជនរងគ្រោះឈ្មោះ [redacted] អូន ភេទប្រុស អាយុ៥០ ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ពុំបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីធ្វើការទាមទារសំណងពីជនជាប់ចោទនោះទេ។ គប្បីតុលាការពុំពិចារណា និងសម្រេចពីសំណងដល់ជនរងគ្រោះនោះឡើយ។

១០-វត្ថុចាប់យកមាន៖

-ម៉ូតូម៉ាកអាសង់កូរ៉េពណ៌ក្រហមពាក់ស្លាកលេខភ្នំពេញ 1D-5107 (របស់ឈ្មោះ [redacted] ប្រុសម៉ី) គប្បីតុលាការសម្រេចរឹបអូសជាសម្បត្តិរដ្ឋ។

## ហេតុដូច្នេះសម្រេច

**១.ផ្តន្ទាទោសលើ**

ក.ឈ្មោះ [redacted] **រក្សា ហៅ ហ៊ីង** ភេទប្រុស អាយុ១៦ ឆ្នាំ ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារកំណត់ **០១(មួយ)ឆ្នាំ**។

ខ.ឈ្មោះ [redacted] **ប្រុសម៉ី** ភេទប្រុស អាយុ២៣ ឆ្នាំ ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារកំណត់ **០២(ពីរ)ឆ្នាំ**។



Scanned with CamScanner

ពីបទ លួច (ដោះគ្រឿងបំណែកម៉ាស៊ីនបូមខ្សាច់) និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិស្រែខ្សាច់ ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣ បទល្មើសដែលបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**២.វត្ថុចាប់យករួមមាន៖**

-ម៉ូតូម៉ាកអាសង់កូរ៉េពណ៌ក្រហមពាក់ស្លាកលេខភ្នំពេញ 1D-5107 (របស់ឈ្មោះ [redacted] ប្រុសម៉ី) ត្រូវរឹបអូសជាសម្បត្តិរដ្ឋ។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] រក្សា ហៅ ហ៊ីង និងឈ្មោះ [redacted] ប្រុសម៉ី និងប្រកាសជាសាធារណៈនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់៕

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា |

[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ៤កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

កណ្តាល, ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner